**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៦៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជីវសុវត្ថិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៥៨អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីយន្តការនិងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជីវសុវត្ថិភាពដែលសរសេរកាត់ថា លេខាធិការដ្ឋាន **គ.ជ.ជ.ស.**។ លេខាធិការដ្ឋាន **គ.ជ.ជ.ស.** នេះមានឋានៈស្មើនាយកដ្ឋាន។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា ២.-**

លេខាធិការដ្ឋាន **គ.ជ.ជ.ស.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូន **គ.ជ.ជ.ស.** និងក្រុមវិទ្យាសាស្ត្រពិគ្រោះយោបល់(**ក.វ.ព.យ.**)
- ពិនិត្យលក្ខណសម្បត្តិនៃឯកសារសុំប្រើប្រាស់សពាង្គកាយកែច្នៃរស់ ឯកសារវាយតម្លៃហានិភ័យ និងលទ្ធផលវាយតម្លៃហានិភ័យ
- រក្សាព័ត៌មានសម្ងាត់
- រៀបចំកិច្ចប្រជុំនិងសិក្ខាសាលាពាក់ព័ន្ធនានានៃ **គ.ជ.ជ.ស.** និង **ក.វ.ព.យ.** ព្រមទាំងក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យ
- ស្រាវជ្រាវពីជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប
- លើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជនផ្នែកជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប
- ធ្វើបច្ចុប្បន្នកម្មបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពជាតិ
- សម្របសម្រួលនិងប្រឹក្សាយោបល់លើវិវាទផ្នែកលំហូរនៃហ្សែនរុក្ខជាតិ សត្វ និងអតិសុខុមប្រាណក្នុងការយកមកដាំដុះឬចិញ្ចឹម
- ធ្វើសេចក្តីរាយការណ៍ជូន **គ.ជ.ជ.ស.** និង **ក.វ.ព.យ.** ព្រមទាំងក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យអំពីការអនុវត្តកាតព្វកិច្ចនៃពិធីសារកាតាហេហ្សណាស្តីពីជីវសុវត្ថិភាព
- ចងក្រងទិន្នន័យអំពីសកម្មភាពឬប្រតិបត្តិការទាក់ទងនឹងការផលិត ការដាំដុះ និងការចិញ្ចឹមសពាង្គកាយកែច្នៃរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរាយការណ៍ជូន **គ.ជ.ជ.ស.**
- រៀបចំវគ្គបណ្តុះបណ្តាលពីបច្ចេកទេសវាយតម្លៃហានិភ័យ បច្ចេកទេសគ្រប់គ្រងហានិភ័យ វិធានការទប់ស្កាត់ និងគ្រប់គ្រងការសាយភាយនៃសពាង្គកាយកែច្នៃរស់
- ធ្វើសេចក្តីព្រាងនិងអភិវឌ្ឍគោលនយោបាយ បទប្បញ្ញត្តិ និងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែងនៃជីវសុវត្ថិភាព ដើម្បីទប់ស្កាត់រាល់ហានិភ័យដែលកើតចេញពីការប្រើប្រាស់សពាង្គកាយកែច្នៃរស់ ដែលអាចប៉ះពាល់ដល់ជីវៈចម្រុះ សុខភាពមនុស្ស និងបរិស្ថាន
- ទទួលអនុវត្តគម្រោងទាក់ទងនឹងជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប
- ផ្តល់យោបល់ជូន **គ.ជ.ជ.ស.** លើការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនានា ទាក់ទងនឹងពិធីសារកាតាហេហ្សណាស្តីពីជីវសុវត្ថិភាព
- លើកសំណើបញ្ជ្រាបគោលនយោបាយជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើបទៅក្នុងវិស័យពាក់ព័ន្ធ
- ពង្រឹងសមត្ថភាពធនធានមនុស្សនិងសម្របសម្រួលកៀរគរធនធាន ដើម្បីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាពឲ្យមានប្រសិទ្ធភាព
- ទទួលបំពេញភារកិច្ចផ្សេងៗទៀតដែលប្រធាន **គ.ជ.ជ.ស.** ប្រគល់ជូន។

## ជំពូកទី៣
## ការគ្រប់គ្រង

**មាត្រា ៣.-**

លេខាធិការដ្ឋាន **គ.ជ.ជ.ស.** ដឹកនាំដោយលេខាធិការ០១រូប អមដោយលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់។ ការរៀបចំរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗចំណុះ លេខាធិការដ្ឋាន **គ.ជ.ជ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ជ.ស.**។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ឧសភា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ